ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងដឹកនាំគណៈប្រតិភូអញ្ជើញទៅចូលរួម " **សម័យប្រជុំលើកទី៧២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ** " និងកិច្ចប្រជុំផ្សេងៗទៀត ដែលនឹងប្រព្រឹត្តទៅ ពីថ្ងៃទី **១៩** ដល់ថ្ងៃទី **២៥ ខែកញ្ញា ឆ្នាំ២០១៧** នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** នឹងអញ្ជើញធ្វើសេចក្តីថ្លែងការណ៍នៅក្នុងសម័យប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៧២ ដោយផ្តោតទៅលើសារៈសំខាន់នៃកិច្ចប្រឹងប្រែងរួមក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងភេរវកម្ម សមិទ្ធផលរបស់កម្ពុជាស្តីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងកិច្ចប្រឹងប្រែងរបស់របស់កម្ពុជាឆ្ពោះទៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព។ បញ្ហាតំបន់ និងអន្តរជាតិដែលជាការព្រួយបារម្ភរួម និងការវិវត្តនាពេលថ្មីៗនៅកម្ពុជា ក៏នឹងត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នេះដែរ។

គណៈប្រតិភូកម្ពុជា នឹងចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រោមក្របខ័ណ្ឌអង្គការប្រទេសនិយាយភាសាបារាំង ចលនាមិនចូលបក្សសម្ព័ន្ធ សន្និសិទស្តីពីអន្តរកម្ម និងវិធានការកសាងទំនុកចិត្តនៅអាស៊ី កិច្ចសន្ទនាសហប្រតិបត្តិការនៅអាស៊ី ក្រុមប្រទេស៧៧ ប្រទេសដែលមានការអភិវឌ្ឍយឺត កិច្ចប្រជុំក្រៅផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ និងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

នៅក្នុងឱកាសចូលរួមសម័យប្រជុំលើកទី៧២ នៃមហាសន្និបាតអង្គការសហប្រជាជាតិនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ក៏នឹងមានជំនួបទ្វេភាគីជាមួយសមភាគីរបស់ឯកឧត្តមពីគុយបា កូឡុំប៊ី ប្រេស៊ីល ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងឥស្សរជនដទៃទៀត។

ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏នឹងចុះហត្ថលេខាជាមួយសមភាគីរបស់ឯកឧត្តម មកពីប្រទេសប្រេស៊ីល និងកូឡុំប៊ី លើឯកសារចំនួនពីរ ខាងក្រោម:

១)កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធប្រេស៊ីល និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស។

២)កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូឡុំប៊ី ស្តីពីការលើកលែងទិដ្ឋាការសំរាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៧


អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh